**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០២៥

**សូមផ្ញើជូន**
**ឯកឧត្តម MOHAMED KHALED NORDIN រដ្ឋមន្ត្រីក្រសួងការពារជាតិ**
**នៃប្រទេសម៉ាឡេស៊ី**

"គូឡាឡាំពួរ"

ឯកឧត្តម ជាទីគោរពរាប់អាន!

ជាបឋម តាងនាមឱ្យនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ **ឯកឧត្តម** ជាពិសេសចំពោះតួនាទីដ៏សំខាន់របស់ប្រទេសម៉ាឡេស៊ីក្នុងនាមជាប្រធានប្តូរវេនអាស៊ាន និងជាប្រធានក្រុមអ្នកអង្កេតការណ៍អាស៊ាន បន្ទាប់ពីបញ្ចប់ដោយជោគជ័យ នៃកិច្ចប្រជុំវិសាមញ្ញគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ (GBC) កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

ក្រោមការដឹកនាំរបស់ **ឯកឧត្តម** និងការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួនរបស់ប្រទេសម៉ាឡេស៊ីបានរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវកិច្ចព្រមព្រៀងឈប់បាញ់ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ក៏ដូចជាក្នុងការជំរុញទំនុកចិត្ត មានការយោគយល់គ្នាទៅវិញទៅមក និងការដោះស្រាយដោយសន្តិវិធីចំពោះស្ថានការណ៍នៅតាមព្រំដែនរួម កម្ពុជា-ថៃ។ ការចូលរួមក្នុងន័យស្ថាបនានេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពតានតឹង ទប់ស្កាត់ការបាត់បង់អាយុជីវិត និងរងរបួសបន្ថែមទៀត ជាពិសេស នេះគឺជាមូលដ្ឋានគ្រឹះសម្រាប់សន្តិភាព និងស្ថិរភាពយូរអង្វែងនៅក្នុងតំបន់។ ទន្ទឹមនឹងនេះ ខ្ញុំស្នើសុំ **ឯកឧត្តម** ជួយពិនិត្យ និងជំរុញ ការរៀបចំឯកសារក្រមប្រតិបត្តិ (TOR) ឱ្យបានឆាប់រហ័សផងដែរ។

ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា នៅតែប្តេជ្ញាចិត្តធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រទេសម៉ាឡេស៊ី ក៏ដូចជាភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធានាការអនុវត្តនូវបទឈប់បាញ់ប្រកបដោយប្រសិទ្ធភាព និងពេញលេញ និងជំរុញដំណើរការសន្តិភាពក្នុងស្មារតីឯកភាព និងសាមគ្គីភាពអាស៊ាន។

ជាថ្មីម្តងទៀត ខ្ញុំសូមប្រសិទ្ធពរជ័យ បវរសួស្តីមហាប្រសើរ ជូនចំពោះ **ឯកឧត្តម** ព្រមទាំងសហការីទាំងអស់ សូមទទួលបានសុខភាពល្អបរិបូរណ៍ មានសុភមង្គល និងជោគជ័យលើគ្រប់ភារកិច្ច និងសូមជូនពរឱ្យចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងកងទ័ព និងប្រជាជនយើងទាំងពីរ កម្ពុជា-ម៉ាឡេស៊ី ស្ថិតស្ថេរ រឹងមាំ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

*(Unofficial Translations)*

Ministry of National Defence

Phnom Penh, 08 August 2025

**To**
**Your Excellency MOHAMED KHALED NORDIN,**
**Minister of Defence of Malaysia**

**"Kuala Lumpur"**

**Your Excellency,**

First of all, on behalf of commissioned and non-commissioned officer of the Royal Cambodian Armed Forces (RCAF) and myself, I would like to express my heartfelt appreciation to **Your Excellency**, especially regarding Malaysia's esteemed position as the rotating Chair of ASEAN and the Chair of the ASEAN Observer Team (AOT), Following the successful convening of the extraordinary Cambodia-Thailand General Border Committee (GBC) Meeting on 07 August 2025 in Kuala Lumpur, Malaysia.

**Your Excellency**'s leadership and the steadfast commitment of Malaysia have been instrumental in achieving the Ceasefire Agreement of 28 July 2025, as well as in fostering trust, mutual understanding, and a peaceful resolution to the situation along the common border between Cambodia and Thailand. This constructive engagement has contributed significantly to de-escalating tensions, preventing further loss of life and injuries, especially as this lays the foundation for lasting peace and stability in our region. Simultaneously, I respectfully request that **Your Excellency** provide guidance and encourage the prompt development of the Terms of Reference (TOR) document.

The Ministry of National Defence of the Kingdom of Cambodia remains committed to working closely with Malaysia, as well as with all concerned parties, to ensure the full and effective implementation of the ceasefire and to advance the peace process in the spirit of ASEAN unity and solidarity.

Once again, I would like to express my profound appreciation for your assistance and wish you and your colleagues good health, and wish the bonds of solidarity, friendship, and cooperation between our two-armed forces and the people of Cambodia and Malaysia remain firm.

Please accept, **Your Excellency**, the assurances of my sincere appreciation and consideration.

**Deputy Prime Minister, Minister of National Defence**

**(Signed)**

**General TEA SEIHA**